# ព្រះរាជាណាចក្រកម្ពុជា

**តុលាការកំពូល**
*****

**ជាតិ សាសនា ព្រះមហាក្សត្រ**
**********

សំណុំរឿងព្រហ្មទណ្ឌ

លេខ:៦៥

## នាមនាមប្រជារាស្ត្រខ្មែរ

ចុះថ្ងៃទី១០ ខែវិច្ឆកា ឆ្នាំ១៩៩៩

**តុលាការកំពូល**

**សាលដីកា**

លេខ: ១២

ចុះថ្ងៃទី២៣ខែមេសាឆ្នាំ២០០៣

បានបើកសវនាការជំនុំជំរះជាសាធារណៈ នៅថ្ងៃទី២៣ ខែមេសា ឆ្នាំ២០០៣ ដោយមានសមាសភាពក្រុមប្រឹក្សាជំនុំជំរះដូចតទៅ:

១- ឯកឧត្តម **ឃឹម ប៉ុណ្ណ** ប្រធាន

២- លោក ឈឹម ស៊ីផល ចៅក្រម

៣- លោក ជីវ កេង ចៅក្រម

៤- លោក ប៉ែន សាវឿន ចៅក្រម

៥- លោក យស់ សូខឿន ចៅក្រមរបាយការណ៍

**ក្រឡាបញ្ជី**

លោក សាន សុផាត

**តំណាងមហាអយ្យការ**

លោក សាយ សារី ព្រះរាជអាជ្ញា

ដើម្បីជំនុំជំរះលើបណ្តឹងសាទុក្ខពីសាលដីកាព្រហ្មទណ្ឌលេខ១៩៣ ចុះថ្ងៃទី២៨ ខែកក្កដា ឆ្នាំ១៩៩៩ របស់សាលាឧទ្ធរណ៍និងសំណុំរឿងព្រហ្មទណ្ឌលេខ៦៥ ចុះថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ១៩៩៩ របស់តុលាការកំពូល ។

**<u>ចំបទ:</u>** ធ្វើមនុស្សឃាដដោយចេតនាគិតទុកជាមុនប្រព្រឹត្តិនៅភូមិព្រៃកតាគន់ ឃុំស្វាយប៉ោ ស្រុកស្វាយដោ៉ ខេត្តបាត់ដំបង កាលពីថ្ងៃទី២ ខែកក្កដា ឆ្នាំ១៩៩៤ បទល្មើសព្រហ្មទណ្ឌ ដែលមានចែង និង ឱ្យផ្តន្ទាទោស តាមបញ្ញត្តិមាត្រា៣១ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ចុះថ្ងៃទី១០ ខែកញ្ញា ឆ្នាំ១៩៩២ ។

១-ជនជាប់ចោទឈ្មោះស៊ុន ចំរើន (ជាចុងបណ្តឹងសាទុក្ខ) ភេទប្រុស អាយុ២៦ឆ្នាំ ជាតិខ្មែរ របរកស៊ីធ្វើយោធា ទីលំនៅមុនថ្ងៃចាប់ខ្លួនភូមិមោង ឃុំអន្លង់វិល ស្រុកសង្កែ ខេត្តបាត់ដំបង ឪពុកឈ្មោះស៊ុន សុវាត "រ" ម្តាយឈ្មោះសារិន "រ" ប្រពន្ធឈ្មោះកៀក វណ្ណា មានកូន១នាក់ ។ក្រៅឃុំ ។

-មានមេធាវី លោក ប៉ា ងួនគា

២-ជនជាប់ចោទឈ្មោះរុំ សុផា ភេទប្រុស អាយុ២៨ឆ្នាំ ជាតិខ្មែរ របររកស៊ីធ្វើយោធា ទីលំនៅសព្វ

ថ្ងៃផ្ទះលេខ២៥១ ក្រុម១៤ ភូមិអូរមុនី ឃុំអន្លង់វិល ស្រុកសង្កែ ខេត្តបាត់ដំបង ឪពុកឈ្មោះរ៉ុម សាន៍ស" ម្តាយឈ្មោះវ៉ាន់ គឿត ប្រពន្ធឈ្មោះកា មុំ មានកូន២នាក់ ។

-អគ្គព្រះរាជអាជ្ញា អមសាលាឧទ្ធរណ៍(ជាម្ចាស់បណ្តឹងសាទុក្ខ)

-ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះយិន គឹមសេង (ជាចុងបណ្តឹងសាទុក្ខ) ភេទស្រី អាយុ៤៤ឆ្នាំ ជាតិខ្មែរ ទីលំនៅសព្វថ្ងៃភូមិអូរចារ សង្កាត់សាមគ្គី ស្រុកទីរួមខេត្ត ខេត្តបាត់ដំបង ។

-តាមពាក្យបណ្តឹងរបស់ឈ្មោះយិន គឹមសេង ចុះថ្ងៃទី០៣ខែកក្កដាឆ្នាំ១៩៩៤ ប្តឹងពីឈ្មោះស៊ុន ចំរើន និងបក្សពួកប្លន់សំលាប់កូនរបស់ខ្លួនដោយសំអាងហេតុថា នៅថ្ងៃទី០២ ខែកក្កដា ឆ្នាំ១៩៩៤ ឈ្មោះស៊ុន ចំរើន និងឈ្មោះរុំ សុផា នាំគ្នាជិះម៉ូតូNOVAសរំងលាយមកបបួលឈ្មោះសៅ រិទ្ធី ហៅហ៊ីង ទៅហាងពន្លឺត្បូងពេលទៅផឹកស៊ីនោះ ឈ្មោះសៅ រិទ្ធី ហៅហ៊ីងបានជិះម៉ូតូC100សេរីថ្មីពណ៌ក្រើងទុំ ។ក្រោយពីពេលស៊ីផឹករួចវេលាម៉ោង៨ យប់ឈ្មោះស៊ុន ចំរើន និងឈ្មោះរុំ សុផា ព្រមទាំងបក្សពួកបាននាំឈ្មោះសៅ រិទ្ធី យកទៅបាញ់ចោលនៅចំណុចក្រុម៧ ភូមិព្រែកតាគន់ ឃុំស្វាយប៉ោ២ ទីរួមខេត្តបាត់ដំបង ប្លន់យកម៉ូតូតែម្តង ។

-បានឃើញសេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការ អមតុលាការខេត្តបាត់ដំបង ថា : មានភស្តុតាង និងមានពិរុទ្ធគ្រប់គ្រាន់លើឈ្មោះស៊ុន ចំរើន និងឈ្មោះរុំ សុផា ពីបទៈ ធ្វើមនុស្សឃាដដោយចេតនាគិតទុកជាមុនប្រព្រឹត្តនៅភូមិព្រែកតាគន់ សង្កាត់ស្វាយប៉ោ២ ទីរួមខេត្តបាត់ដំបង កាលពីយប់ថ្ងៃទី០២ ខែកក្កដា ឆ្នាំ ១៩៩៤ បទល្មើសព្រហ្មទណ្ឌដែលចែងនិងផ្តន្ទាទោសតាមបញ្ញាតិមាត្រា៣១ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ចុះថ្ងៃទី១០ ខែកញ្ញា ឆ្នាំ១៩៩២ របស់ក្រុមប្រឹក្សាជាតិជាន់ខ្ពស់កម្ពុជា ។ ស្នើសុំតំកល់បទចោទទុកជាបានការពេញទាំងមូល និង ស្នើសុំឱ្យតុលាការសំរេចផ្តន្ទាទោសលើឈ្មោះស៊ុន ចំរើន និងឈ្មោះរុំ សុផា ដាក់ពន្ធនាគារកំណត់ពី១៥ឆ្នាំទៅដល់១៧ឆ្នាំ ។

-បានឃើញសាលក្រមលេខ៤៥ ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ១៩៩៥ របស់តុលាការខេត្តបាត់ដំបង ដែលបានសំរេច :

១-ផ្តន្ទាទោសលើឈ្មោះ ÷

ក-ស៊ុន ចំរើន ភេទប្រុស អាយុ២៧ឆ្នាំ ដាក់ពន្ធ នាគារកំណត់១៥ឆ្នាំគិតពីថ្ងៃឃុំខ្លួន ។

ខ-រុំ សុផា ភេទប្រុស អាយុ២៨ឆ្នាំដាក់ពន្ធនាគារកំណត់១៦ឆ្នាំ គិតពីថ្ងៃចាប់ខ្លួនបានដោយអនុវត្តបន្តដីកាចាប់ខ្លួនលេខ៣៥៨.ច.ខ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ១៩៩៤ របស់ចៅក្រមស៊ើបអង្កេត។

ពីបទៈ ធ្វើមនុស្សឃាដដោយចេតនាគិតទុកជាមុនប្រព្រឹត្តនៅភូមិព្រៃតាគន់ សង្កាត់ស្វាយប៉ោ២ ទីរួមខេត្តបាត់ដំបង កាលពីយប់ថ្ងៃទី០២ ខែកក្កដា ឆ្នាំ១៩៩៤ ។

បទល្មើសព្រហ្មទណ្ឌដែលមានចែងនិងផ្តន្ទាទោសតាមមាត្រា៣១ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ចុះថ្ងៃទី១០-៩០-៩២ របស់ក្រុមប្រឹក្សាជាតិជាន់ខ្ពស់កម្ពុជា ។

២-វត្ថុតាងគឺ:

ក-កាំភ្លើងK៥៩ លេខ៣០៧៦ត្រូវរឹបអូសទុកជាទ្រព្យសម្បត្តិរដ្ឋ ។

ខ-សំបកកាំទូសចំនួនមួយលេខ១១-៦៩ត្រូវរឹមអូសបំផ្លាញចោល ។

៣-បង្គាប់ឱ្យឈ្មោះស៊ុន ចំរើន និងឈ្មោះរុំ សុផា ចេញសំណងការអន្តរាយ និងជំងឺចិត្តដោយគិតជាប្រាក់រៀល ស្មើនឹងមាសទឹកដប់ចំនួន៧តំឡឹងឱ្យដល់ឈ្មោះយិន គីមសេង ជាដើមបណ្តឹងរដ្ឋប្បវេណី ។ ដើមបណ្តឹងទាមទារលើសពីនេះបដិសេធចោល ។

ក្នុងករណីទណ្ឌិតទាំងពីរនាក់គ្មានប្រាក់សងធនទណ្ឌគ្រប់ចំនួនទេនោះ ត្រូវដាក់គុកបង្ខំលើរូបកាយក្នុងរឿងព្រហ្មទណ្ឌកំណត់២ឆ្នាំ ដើម្បីការប្រាក់ធនទណ្ឌតាមមាត្រា៧ នៃច្បាប់ស្តីពីការដាក់គុកបង្ខំលើរូបកាយក្នុងរឿងព្រហ្មទណ្ឌដែលប្រកាសឱ្យប្រើតាមក្រឹត្យលេខ១៨ក្រ ចុះថ្ងៃទី៨-២-៩២ របស់ក្រុមប្រឹក្សារដ្ឋនៃរដ្ឋកម្ពុជា។

៤-សាលក្រមនេះជំនុំជំរះ និងប្រកាសជាសាធារណៈចំពោះមុខជនជាប់ចោទឈ្មោះស៊ុន ចំរើន កំបាំងមុខជនជាប់ចោទឈ្មោះរុំ សុផា និងចំពោះមុខដើមបណ្តឹងរដ្ឋប្បវេណី ។

ទុករយៈពេលប្តឹងទាស់ និងបើកផ្លូវប្តឹងឧទ្ធរណ៍តាមច្បាប់កំណត់ ។

-បានឃើញបណ្តឹងឧទ្ធរណ៍លេខ១៨ ចុះថ្ងៃទី១៥ ខែមីនា ឆ្នាំ១៩៩៥ របស់ឈ្មោះស៊ុន ចំរើន ប្តឹងមិនសុខចិត្តពីសាលក្រមព្រហ្មទណ្ឌលេខ៤៥ ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ១៩៩៥ របស់តុលាការខេត្តបាត់ដំបង លើសេចក្តីសំរេចទាំងមូល ។

-បានឃើញសេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ អមសាលាឧទ្ធរណ៍ ថា: មានលិខិតពីរដែលមេធាវីការពារជនជាប់ចោទលើកយកមកសន្និដ្ឋានដូចជាភស្តុតាងពុំបានគ្រប់គ្រាន់ហើយបញ្ជូនមកសាលាឧទ្ធរណ៍ទេ ហើយសាលាឧទ្ធរណ៍បានចាត់របៀបរកដែល តែមកទល់ពេលនេះពុំមានលទ្ធផលដែរ ។ ផ្អែកតាមឯកសារក្នុងសំណុំរឿងមានការខូចខាតយ៉ាងច្រើនក្នុងការស៊ើបអង្កេតក្នុងបទឃាដកម្មនេះ ការចោទប្រកាន់ក្នុងលក្ខណៈសង្ស័យប៉ុណ្ណោះ ។ ទោះបីឃាដកម្មមិនច្បាស់លាស់ក៏ដោយ សូមកែប្រែបទចោទពីឃាដកម្មគិតទុកជាមុនមកបទប្រើប្រាស់អាវុធខុសច្បាប់ ។

-បានឃើញសាលដីកាព្រហ្មទណ្ឌលេខ១៩៣ ចុះថ្ងៃទី២៨ ខែកក្កដា ឆ្នាំ១៩៩៩ របស់សាលាឧទ្ធរណ៍ដែលបានសំរេច :

១-ទទួលពាក្យបណ្តឹងឧទ្ធរណ៍ចុះថ្ងៃទី១៥ ខែមីនា ឆ្នាំ១៩៩៥ របស់ឈ្មោះស៊ុន ចំរើន ទុកជាត្រឹមត្រូវតាមទំរង់ និងគតិច្បាប់ ។

២-បដិសេធសាលក្រមព្រហ្មទណ្ឌលេខ៤៥ ចុះថ្ងៃទី២៨ ខែមីនា ឆ្នាំ១៩៩៥របស់តុលាការខេត្តបាត់ដំបងចោលជាអាសារបង់ ។

៣-ឱ្យឈ្មោះស៊ុន ចំរើន ភេទប្រុស អាយុ២៧ឆ្នាំ និងឈ្មោះរុំ សុផា ភេទប្រុស អាយុ២៨ឆ្នាំ រួចខ្លួនពីបទធ្វើមនុស្សឃាដគិតទុកជាមុនប្រព្រឹត្តកាលពីថ្ងៃទី០២ ខែកក្កដា ឆ្នាំ១៩៩៤ នៅភូមិព្រៃកតាគន់ សង្កាត់ស្វាយប៉ោ២ ទីរួមខេត្តបាត់ដំបង បទល្មើសព្រហ្មទណ្ឌដែលមានចែងនិងផ្តន្ទាទោសតាមបញ្ញត្តិមាត្រា៣១ច្បាប់ព្រហ្មទណ្ឌអន្តរកាលចុះថ្ងៃទី១០-៩-១៩៩២ ។

៤-បង្គាប់ឱ្យដោះលែងឈ្មោះស៊ុន ចំរើន ភេទប្រុស អាយុ២៧ឆ្នាំ ពីមន្ទីរឃុំឃាំងជាបន្ទាន់ប្រសិនបើឈ្មោះនេះពុំត្រូវបានឃុំខ្លួនពីបទល្មើសអ្វីផ្សេងទៀតនោះ ។

៥-សាលដីកានេះជំនុំជំរះ និងប្រកាសជាសាធារណៈចំពោះមុខមេធាវីការពារជនជាប់ចោទ កំបាំងមុខជនជាប់ចោទ កំបាំងមុខដើមបណ្តឹងរដ្ឋប្បវេណី បើផ្លូវប្តឹងតវ៉ាក្នុងកំណត់ច្បាប់ ។

-បានឃើញបណ្តឹងសាទុក្ខលេខ៨២ ចុះថ្ងៃទី១០ ខែកញ្ញា ឆ្នាំ១៩៩៩ របស់ឯកឧត្តមអគ្គព្រះរាជអាជ្ញា អមសាលាឧទ្ធរណ៍ ប្តឹងមិនសុខចិត្តពីសាលដីកាព្រហ្មទណ្ឌលេខ១៩៣ចុះថ្ងៃទី២៨ ខែកក្កដា ឆ្នាំ១៩៩៩ របស់សាលាឧទ្ធរណ៍ ត្រង់ចំណុចទី៤នៃសេចក្តីសំរេច ។

-បានឃើញសារណា ចុះថ្ងៃទី២៨ ខែមីនា ឆ្នាំ២០០០ របស់ឯកឧត្តមអគ្គព្រះរាជអាជ្ញា (ជាម្ចាស់បណ្តឹងសាទុក្ខ) ធ្វើឡើងក្នុងកំណត់ច្បាប់ ។

-បានឃើញលិខិតបង្គាប់ឱ្យធ្វើសារណាតបចុះថ្ងៃទី១៤ ខែកុម្ភ ឆ្នាំ២០០១ របស់តុលាការកំពូល បង្គាប់ឱ្យឈ្មោះស៊ុន ចំរើន ជាចុងបណ្តឹងសាទុក្ខធ្វើសារណាឆ្លើយតបដោះសារពីសារណារបស់ឯកឧត្តមអគ្គព្រះរាជអាជ្ញា អមសាលាឧទ្ធរណ៍ ហើយដែលរដ្ឋអំណាចមូលដ្ឋានបានទទួលថ្ងៃទី៥ ខែមីនា ឆ្នាំ២០០១ និងបញ្ជាក់ថាចំពោះឈ្មោះស៊ុន ចំរើន សព្វថ្ងៃពុំនៅក្នុងមូលដ្ឋានទេ ដែលជាហេតុធ្វើឱ្យគ្មានសារណាឆ្លើយតបរបស់ចុងបណ្តឹងសាទុក្ខតាមកំណត់ច្បាប់ ។

-បានស្តាប់របាយការណ៍ របស់ចៅក្រមរបាយការណ៍

-បានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ អមតុលាការកំពូល ថាៈ សាលាឧទ្ធរណ៍សំរេចសេចក្តីមកនេះមានការខុសឆ្គង សូមបដិសេធសាលាដីកាសាលាឧទ្ធរណ៍ចោលជាអសារ ។

-បានស្តាប់អំណានសារណារបស់ឯកឧត្តមអគ្គព្រះរាជអាជ្ញា អមសាលាឧទ្ធរណ៍នៅពេលជំនុំជំរះ ។

-បានស្តាប់សេចក្តីសន្និដ្ឋានការពាររបស់លោកប៉ា ងួនតា មេធាវីការពារជនជាប់ចោទឈ្មោះស៊ុន ចំរើន (ជាចុងបណ្តឹងសាទុក្ខ) នៅពេលជំនុំជំរះ ថាៈ ក្នុងរឿងនេះភស្តុតាងមិនស៊ីចង្វាក់គ្នា កូនក្តីខ្ញុំមិនបានប្រព្រឹត្តិបទល្មើសទេ សូមតុលាការកំពូលតម្កល់សាលដីកាសាលាឧទ្ធរណ៍ទុកជាបានការដដែល ។

-បានស្តាប់សេចក្តីសន្និដ្ឋានបន្ថែមនាពេលសវនាការ របស់តំណាងមហាអយ្យការ អមតុលាការកំពូលថាៈ សូមរក្សាបទចោទប្រកាន់នៅដដែល។

-ក្រោយពីបានស្តាប់របាយការណ៍របស់ចៅក្រមរបាយការណ៍

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ

-ក្រោយពីបានស្តាប់សារណារបស់អគ្គព្រះរាជអាជ្ញា អមសាលាឧទ្ធរណ៍ និងសេចក្តីសន្និដ្ឋានការពាររបស់មេធាវីជនជាប់ចោទ ។

-ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ

## <u>តុលាការកំពូល</u>

-យល់ឃើញថា បណ្តឹងសាទុក្ខលេខ៨២ ចុះថ្ងៃទី១០ ខែកញ្ញា ឆ្នាំ១៩៩៩ របស់អគ្គព្រះរាជអាជ្ញា

សាលាឧទ្ធរណ៍ធ្វើឡើងក្នុងកំណត់ច្បាប់តុលាការកំពូលអាចលើករឿងនេះមកជំនុំជំរះបានតាមមាត្រា១៤នៃច្បាប់ស្តីពីការចាត់តាំង និងសកម្មភាពរបស់សាលាជំរះក្តី ។

-យល់ឃើញថា ការដែលសាលាឧទ្ធរណ៍សំរេចឱ្យជនជាប់ចោទឈ្មោះស៊ុន ចំរើន និងរ៉ុំ សុផា រួចខ្លួនពីបទធ្វើមនុស្សឃាដដោយចេតនាគិតទុកជាមុនប្រព្រឹត្តិនៅភូមិព្រៃកតាគន់ សង្កាត់ស្វាយប៉ោ២ ស្រុកទីរួម ខេត្តបាត់ដំបង កាលពីថ្ងៃទី២ ខែកក្កដា ឆ្នាំ១៩៩៤ ដោយសំអាងលើលិខិតលេខ១១៣ របក.តប ចុះថ្ងៃទី ១៣ ខែវិច្ឆិកា ឆ្នាំ១៩៩៧ របស់ស្នងការនគរបាលខេត្ត ដែលពិនិត្យតែលើបញ្ជីកាន់កាប់អាវុធនោះគឺមិនទាន់មូលនៅឡើយទេ ពីព្រោះមានសាក្សីឈ្មោះឆឹយ វិសាល,ហោឌីម៉ង់,ស្រីគឹមយេង បានឆ្លើយបញ្ជាក់ច្បាស់ថាពិតជាបានឃើញឈ្មោះស៊ុន ចំរើន ធ្លាប់ប្រើប្រាស់អាវុធខ្លីធុនK៥៤ប្រាកដមែន ហើយសាលាឧទ្ធរណ៍ក៏ដូចតុលាការបាត់ដំបងដែរ មិនទាន់បានអោយសមត្ថកិច្ចស្រាវជ្រាវរកកាំភ្លើងធុន K៥៤ដែលជនល្មើសធ្លាប់ប្រើប្រាស់ឡើយ។ ប៉ុន្តែតុលាការកំពូលពុំមានសមត្ថកិច្ចទុកជាមោឃៈចំណុចនេះបានឡើយ ពីព្រោះអគ្គព្រះរាជអាជ្ញាពុំបានប្តឹងសាទុក្ខលើចំណុចនោះទេ គឺប្តឹងសាទុក្ខតែលើចំណុចទី៤ប៉ុណ្ណោះ ។ ដូច្នេះក្រៅពីចំណុចទី៤ចំណុចផ្សេងទៀត នៃសាលដីកាសាលាឧទ្ធរណ៍បានចូលជាស្ថាពរហើយ ។

-យល់ឃើញថា សាលាឧទ្ធរណ៍បង្គាប់ឱ្យដោះលែងជនជាប់ចោទឈ្មោះស៊ុន ចំរើន ជាបន្ទាន់ពីមន្ទីរឃុំឃាំងដែលស្ថិតក្នុងរយៈពេលសាទុក្ខនោះ គឺរំលោភលើមាត្រា២១៧នៃច្បាប់ស្តីពីនិតិវិធីព្រហ្មទណ្ឌ ដោយមាត្រានេះចែងច្បាស់ថា បណ្តឹងសាទុក្ខ និង រយៈពេលសំរាប់ប្តឹងសាទុក្ខមានអនុភាពផ្អាកការអនុវត្តសាលដីកាសាលាឧទ្ធរណ៍ រហូតដល់ថ្ងៃចេញសាលដីការបស់តុលាការកំពូល ប៉ុន្តែដោយកំហុសនេះ ជាកំហុសអង្គច្បាប់សុទ្ធសាធ ដូច្នេះតុលាការកំពូលទុកជាមោឃៈដោយឥតបង្វិលនូវចំណុចទី៤នេះ ។

-យល់ឃើញថា តុលាការកំពូលបានបង្គាប់ឱ្យជនជាប់ចោទធ្វើសារណាតប និងបានកោះហៅមកចូលរួមសវនាការនេះដែរ ប៉ុន្តែរកជនជាប់ចោទពុំឃើញ ដូច្នេះតុលាការកំពូលជំនុំជំរះកំបាំងមុខជនជាប់ចោទចាត់ទុកជាចំពោះមុខ ។

-យល់ឃើញថា ដើមបណ្តឹងរដ្ឋប្បវេណីពុំបានធ្វើសារណា និង ពុំបានមកចូលរួមនាសវនាការនេះទេ ដូច្នេះតុលាការកំពូល ជំនុំជំរះកំបាំងមុខ ចាត់ទុកជាចំពោះមុខ ។

-យល់ឃើញថា សាលដីកាព្រហ្មទណ្ឌលេខ១៩៣ ចុះថ្ងៃទី២៨ ខែកក្កដា ឆ្នាំ១៩៩៩ របស់សាលាឧទ្ធរណ៍ដែលបានសំរេចសេចក្តីមកនេះ មានការខុសឆ្គងទាំងទំរង់ ទាំងគតិច្បាប់ ។

**ហេតុដូច្នេះ**

**វិនិច្ឆ័យសេចក្តី កំបាំងមុខជនជាប់ចោទ និង**

**ដើមបណ្តឹងរដ្ឋប្បវេណី ប៉ុន្តែចាត់ទុកជាចំពោះមុខ**

១-ទទួលបណ្តឹងសាទុក្ខលេខ៨២ ចុះថ្ងៃទី១០ ខែកញ្ញា ឆ្នាំ១៩៩៩ របស់អគ្គព្រះរាជអាជ្ញា សាលាឧទ្ធរណ៍ទុកជាត្រឹមត្រូវតាមទំរង់ និងគតិច្បាប់ ។

២-ទុកជាមោឃៈចំណុចទី៤ នៃសាលដីកាព្រហ្មទណ្ឌលេខ១៩៣ ចុះថ្ងៃទី២៨ ខែកក្កដា ឆ្នាំ១៩៩៩ របស់សាលាឧទ្ធរណ៍ដោយឥតបង្វិល ។

៣-សាលដីកានេះប្រកាសនាសវនាការជាសាធារណៈនៅថ្ងៃទី២៣ ខែមេសា ឆ្នាំ២០០៣ ។